# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤១ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពក្រុមការងារ
## រៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សេចក្តីសម្រេចលេខ ១៦១សសរ. ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុមការងាររៀបចំក្របខ័ណ្ឌនិងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច
- លិខិតលេខ ៧៧២ សជណ.ហធ ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ១ .-**

ត្រូវបានកែសម្រួលសមាសភាពក្រុមការងាររៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដែលត្រូវបានបង្កើតដោយសេចក្តីសម្រេចលេខ ១៦១សសរ. ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុមការងាររៀបចំក្របខ័ណ្ឌនិងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច នៅតាមក្រសួង ស្ថាប័ន ដែលមានសមាសភាពដូចខាងក្រោម÷



https://www.moj.gov.kh/kh/law-regular

| | | |
|---|---|---|
| ១.ឯកឧត្តម **ទី តាយី** | រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២.ឯកឧត្តម **ហ៊ែល ចំរើន** | រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣.ឯកឧត្តម **ឆាយ រតនៈ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៤.ឯកឧត្តម **ឈឹម សៅគី** | រដ្ឋលេខាធិការប្រចាំការ នៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៥.ឯកឧត្តម **សេង សុមុនី** | រដ្ឋលេខាធិការប្រចាំការ នៃក្រសួងធម្មការ និងសាសនា | សមាជិក |
| ៦.ឯកឧត្តមនាយឧត្តមសេនីយ៍ **ដាំ ដារ៉ារិទ្ធ** | រដ្ឋលេខាធិការ នៃក្រសួងការពារជាតិ | សមាជិក |
| ៧.ឯកឧត្តម **អង មង្គល** | រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៨.ឯកឧត្តម **ហេង ចាន់ឌី** | រដ្ឋលេខាធិការ នៃក្រសួងអធិការកិច្ច | សមាជិក |
| ៩.លោកជំទាវ **ដួង សារុន** | រដ្ឋលេខាធិការ នៃក្រសួងផែនការ | សមាជិកា |
| ១០.ឯកឧត្តម **អ៊ុង បូរាត** | រដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១.ឯកឧត្តម **មួន ឋាសនា** | រដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២.ឯកឧត្តម **សុខ ផេង** | រដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៣.ឯកឧត្តម **សុខ សំអាង** | រដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល | សមាជិក |
| ១៤.ឯកឧត្តម **គីម សុន** | រដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៥.ឯកឧត្តម **ឃឹម សិរីចន្ទ** | រដ្ឋលេខាធិការ នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៦.ឯកឧត្តម **ម៉ម អំណាត់** | រដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៧.ឯកឧត្តម **ឌ៉ូច បូរីណា** | រដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន | សមាជិក |
| ១៨.លោកជំទាវ **ខៀវ សុផានី** | រដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិកា |
| ១៩.ឯកឧត្តម **សុខ សប្បាយណា** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ២០.ឯកឧត្តម **អ៊ុន ម៉ាល់ឡឺរ៉ូ** | រដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២១.ឯកឧត្តម **គីម ឆូច** | រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ២២.ឯកឧត្តម **ចុយ រិទ្ធ** | រដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៣.ឯកឧត្តម **ឱម សំអ៊ែល** | អនុរដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៤.ឯកឧត្តម **សែន គុសល** | អនុរដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២៥.ឯកឧត្តម **ស៊ាង ផល្លា** | អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានលេខាធិការដ្ឋាន នៃក្រុមប្រឹក្សានីតិកម្ម កសហវ | សមាជិក |



https://www.moj.gov.kh/kh/law-regular

| | | |
|---|---|---|
| ២៦.ឯកឧត្តម **ចាន់ ពុទ្ធារិទ្ធ** | ទីប្រឹក្សា នៃក្រសួងព័ត៌មាន | សមាជិក |
| ២៧.លោកជំទាវ **ជា ហ៊ីង** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃក្រសួងកិច្ចការនារី | សមាជិកា |
| ២៨.លោក **រស់ សុខណារុណា** | អនុប្រធានលេខាធិការដ្ឋាន នៃក្រុមប្រឹក្សានីតិកម្ម កសហវ | សមាជិក |
| ២៩.លោក **ឈុំ ប៊ុណ្ណារិទ្ធ** | អគ្គាធិការរង នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៣០.លោកស្រី **ញ៉ឹម សុគា** | អគ្គាធិការរង នៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិកា |
| ៣១.លោកស្រី **ទ៉ែត ម៉ូទីឡែន** | អគ្គនាយករង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិកា |
| ៣២.លោកស្រី **ផាន់ ច័ន្ទលី** | ប្រធាននាយកដ្ឋាន នៃក្រសួងយុត្តិធម៌ | សមាជិកា |
| ៣៣.លោក **នុន រាសី** | ប្រធាននាយកដ្ឋាន នៃក្រសួងព័ត៌មាន | សមាជិក |
| ៣៤.លោក **សុខ ច័ន្ទកិត្យា** | ប្រធានផ្នែក នៃលេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម កសហវ | សមាជិក |
| ៣៥.នាយកដ្ឋានរដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្តឹង នៃអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | លេខាធិការដ្ឋាន។ |

**ប្រការ២.-**

ក្រុមការងាររៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច មានភារកិច្ចដូចតទៅ÷

- ពិនិត្យ និងសិក្សាអំពីលិខិតបទដ្ឋានគតិយុត្តជាធរមាន ពាក់ព័ន្ធមុខងារ និងភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅតាមក្រសួង-ស្ថាប័ន
- សិក្សាស្រាវជ្រាវ និង/ឬធ្វើទស្សនកិច្ចសិក្សាអំពីបទពិសោធន៍ និងឧត្តមានុវត្តន៍អន្តរជាតិ ពាក់ព័ន្ធការអនុវត្តមុខងារ និងភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- កំណត់បញ្ហាប្រឈមនៃការអនុវត្តមុខងារ និងភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅតាមក្រសួង-ស្ថាប័ន
- លើកសំណើដំណោះស្រាយអំពីការរៀបចំក្របខ័ណ្ឌមុខងារនៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- រៀបចំក្របខ័ណ្ឌ និងវិធាននៃការបែងចែកមុខងារ និងភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់រាជរដ្ឋាភិបាល។

**ប្រការ៣.-**

ក្រុមការងារនេះ ត្រូវបំពេញការងាររបស់ខ្លួនក្រោមការណែនាំ និងដឹកនាំផ្ទាល់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។



https://www.moj.gov.kh/kh/law-regular

**ប្រការ៤ .-**

សមាជិកក្រុមការងារ នៃក្រុមការងាររៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធាន ដឹកនាំការងារជំនួសតាមការផ្ទេរសិទ្ធិរបស់ប្រធាន។

**ប្រការ៥ .-**

ក្រុមការងាររៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច អាចអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រសួងស្ថាប័នពាក់ព័ន្ធដែលមិនមែនជាសមាជិក ឱ្យចូលរួមប្រជុំតាមតម្រូវការចាំបាច់នៃការងារ។

ក្រុមការងារនេះអាចធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូ និងអ្នកជំនាញការជាតិ និងអន្តរជាតិ ដើម្បីធានានូវប្រសិទ្ធភាពនៃការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

**ប្រការ៦ .-**

សេចក្តីសម្រេចលេខ ១៦១សសរ. ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុមការងាររៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអធិការកិច្ច រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular